LONG BEACH
UNIFIED SCHOOL DISTRICT

# គម្រោងបណ្តើមគំនិតសម្រាប់ឧត្តមភាព និង សមធម៌ 2021-2022

| បណ្តើមគំនិតសម្រាប់សមធម៌ | គោលដៅ | ដឹកនាំដោយ | 2021-2022<br>*តើលទ្ធផលជោគជ័យនឹងបង្ហាញដូចជាអ្វីនៅក្នុងឆ្នាំនេះ?* |
|---|---|---|---|
| **សម្លេង និង ការរួមចំណែកពីសិស្ស** | គោលដៅនៃសម្លេង និង ការរួមចំណែកពីសិស្ស គឺរាប់បញ្ចូលយ៉ាងសកម្មអំពីសម្លេងនៃសិស្សក្នុងការសម្រេចមកលើអ្វីទាក់ទងបទពិសោធន៍របស់ពួកគេនៅក្នុងបន្ទប់រៀន និង សាលារៀន ការរៀបចំមេរៀនក្នុង ឌីស្រ្ទីគ ស្របតាមការស្ទង់វាស់មតិពីក្រុមរួមចំណែកនៃសិស្ស និង ការវិភាគនៃតំណាងជាសិស្ស ។ | ការិយាល័យនៃឧបអគ្គនាយកសាលារៀន | • បន្តជាមួយក្រុមដឹកនាំផ្នែកសមធម៌នៃសិស្ស ដែលមានជាអ្នកតំណាងមកពីវិទ្យាល័យគ្រប់កន្លែង<br>• ធ្វើការទាក់ទងជាមួយសិស្សតាមរយៈទទួលគោលយោបល់មកលើបណ្តើមគំនិតសំខាន់ៗសម្រាប់សមធម៌<br>• ធ្វើកិច្ចការជាមួយសិស្សសម្រាប់ទទួលជាគោលយោបល់មកវិញអំពីសុវត្ថិភាពនៅតាមសាលារៀន រួមទាំងក្រសួងថ្នាក់លើ និង សហគមន៍ជាដៃគូ<br>• បំពេញកិច្ចការជាមួយនាយកសាលារៀនសម្រាប់ទទួលជាគោលយោបល់មកពីសិស្ស ដែលគាំទ្រមកលើគោលដៅ និង មុខងារនៃសាលារៀន |
| **ការត្រួតមើល និង ការផ្តល់ជំនួយសម្រាប់នាយកសាលារៀន** | គោលដៅនៃផ្នែកសមធម៌ គឺធ្វើការសង្កត់មកលើការត្រួតមើលនាយកសាលារៀន ដើម្បីបណ្តុះបណ្តាលជាចំណេះ និង ទាមទារអោយពួកគេធ្វើការទទួលខុសត្រូវមកលើលទ្ធផលជោគជ័យសម្រាប់សិស្សទាំងអស់ ។ | ការិយាល័យនៃអគ្គនាយកសាលារៀន | • នាយក និង អនុនាយកសាលារៀននឹងធ្វើការស្ទង់វាស់អំពីសមត្ថភាពរបស់ខ្លួន ស្របតាមវិស័យ និង ទំហំកែសម្រួលសម្រាប់ភាពលូតលាស់ជាបន្ត<br>• អ្នកត្រួតមើលនាយកសាលារៀននឹងធ្វើការស្ទង់វាស់សមត្ថភាពនៃនាយកសាលារៀន ស្របតាមវិស័យ និង ទំហំ ហើយនាយកសាលារៀននឹងធ្វើការស្ទង់វាស់សមត្ថភាពទៅកាន់អនុនាយកសាលារៀន ស្របតាមវិស័យ និង ទំហំកែសម្រួលសម្រាប់ភាពលូតលូតជាបន្ត<br>• នាយក និង អនុនាយកសាលារៀននឹងយល់ដឹងអំពីលក្ខណ រួមទាំងអាចធ្វើការស្វែងរកបានអំពីមធ្យោបាយដោះស្រាយបញ្ហាទាក់ទងផ្នែកវប្បធម៌ និង ចម្លើយនៅក្នុងសាលារៀន<br>• នាយក និង អនុនាយកសាលារៀននឹងបង្ហាញភាពលូតលាស់នៅតាមសាលារៀនរបស់ពួកគេ ស្របតាមគម្រោងបង្កើតកិច្ចការជាសមធម៌ |
| **ជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្ត** | គោលដៅនៃជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្ត (Transformative Social Emotional Learning – T-SEL) គឺបង្កើនភាពលូតលាស់ ដែល ...<br>• ធ្វើអោយម្នាក់ៗទទួលការយកចិត្តទុកដាក់មកកាន់ ទទួលការផ្តល់តម្លៃ និង មានក្រុមចេះជួយយករក្សាគ្នាទៅវិញទៅមក<br>• អត្តសញ្ញាណ និង គុណសម្បត្តិនៃសិស្ស គឺត្រូវបានទទួលស្គាល់ ទទួលការបញ្ជាក់ ទទួលសេចក្តីគោរព និង ទទួលការផ្តល់តម្លៃ<br>• ការប្រើអំពើយុត្តិធម៌ - ការអនុវត្តន៍ និង មធ្យោបាយបង្ហាញការគាំទ្រនៅក្នុងសហគមន៍<br>• សិស្ស និង មនុស្សធំមានឱកាសសម្រាប់អនុវត្តន៍តាម និង បង្ហាញសមត្ថភាពមកលើបញ្ហាផ្សេងៗទាក់ទងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត | ការិយាល័យ<br>School Support Services & Office of Curriculum, Instruction & Professional Development | • គ្រូបង្រៀន និង នាយកសាលារៀននឹងបង្កើតចំណេះយល់ដឹងផ្នែក CASEL & SEL អំពីសិស្ស ដើម្បីនាំមកជាលទ្ធផលល្អជាជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅកាន់សិស្សតាមរយៈកម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវ<br>• ការបណ្តុះចំណេះសម្រាប់គ្រូបង្រៀន និង នាយកដឹកនាំអំពីមធ្យោបាយបង្ហាញភាពលូតលាស់តាមរយៈចូលរួមក្នុងកម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវ<br>• បណ្តើមគំនិតមកលើការប្រើបន្តជាជំនួយរាប់បញ្ចូលគ្នាសម្រាប់គាំទ្រទៅកាន់ការប្រើវិន័យអប់រំជាកម្រិតថ្នាក់ Tier I-III ការបង្កើតប្រើជាអំពើយុត្តិធម៌ឡើងវិញ និង ការបណ្តុះភាពទទួលស្គាល់មកលើអត្តសញ្ញាណ<br>• រាប់បញ្ចូលគោលដៅនៃការអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅជាមួយមេរៀនដ៏សំខាន់សម្រាប់ថ្នាក់ជ្រើសរើសរៀនជាមួយ និង ការបង្ហាត់មេរៀន<br>• បង្កើត និង ប្រើការចែកផ្តល់ជាជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅកាន់មនុស្សធំ<br>• សិស្ស មាតាបិតា និង បុគ្គលិកនឹងរៀនទទួលស្គាល់ដូចគ្នាអំពីជំនួយ ដែលនឹងចែកផ្តល់ដោយមណ្ឌល Care/Wellness Centers ស្ថិតនៅតាមវិទ្យាល័យរបស់យើង |
| **ទំនាក់ទំនងជាមួយសហគមន៍** | គោលដៅនៃទំនាក់ទំនងជាមួយសហគមន៍ គឺបណ្តុះ និង កសាងជាជំនឿទុកចិត្តជាមួយក្រុមរួមចំណែកទាំងអស់ បង្កើតជាប្រព័ន្ធសម្រាប់ផ្តល់ឱកាសទទួលជាគោលយោបល់ច្រើនចំណែកមកវិញ ដើម្បីរាយផ្សាយ និង បង្កើនមធ្យោបាយកាន់តែប្រសើរសម្រាប់ក្រសួងអប់រំ ឌីស្រ្ទីគ ធ្វើទំនាក់ទំនងជាមួយមាតាបិតា ។ | ការិយាល័យ<br>Equity, Engagement & Partnerships | • គាំទ្រមកលើការបង្កើត និង ការទទួលស្គាល់កិច្ចការទាក់ទង គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់ តាមរយៈផ្តល់ជាដំណើរការផ្នែករួមចំណែកផ្សេងៗ<br>• គាំទ្រមកលើការបង្កើតកិច្ចការនៃ ក្រុមដឹកនាំផ្នែកសមធម៌<br>• ទាក់ទាញការរួមចំណែកពីក្រុមរួមចំណែកទាំងអស់ក្នុងដំណើរការពិគ្រោះអំពីថវិកា<br>• រក្សាទុកអំពីលទ្ធផលទាក់ទងការរួមចំណែកជាមួយសហគមន៍ ការទទួលជាគោលគំនិត និង អនុសាសន៍ផ្សេងៗមកវិញ<br>• កម្មវិធីចាក់បង្ហាញជាច្រើនលើកដោយការិយាល័យ Parent University ដែលសមស្របតាមបណ្តើមគំនិតសំខាន់ៗ |
| **ការបណ្តុះបណ្តាលកម្មវិធី និង ការហ្វឹកហ្វឺន** | គោលដៅនៃកម្មវិធី និង ការបណ្តុះបណ្តាលកម្មវិធីហ្វឹកហ្វឺន គឺគាំទ្រទៅកាន់គ្រូបង្រៀន និង នាយកដឹកនាំអំពីការបង្កើតសមត្ថភាពជា ប្រាំបី ចំណែកសម្រាប់ដោះស្រាយទៅលើការបង្ហាត់ទាក់ទងផ្នែកវប្បធម៌ និង ការរៀបចំកម្មវិធីទាក់ទងស្របវប្បធម៌ ។ | ការិយាល័យ<br>Office of Curriculum, Instruction & Professional Development | • ផ្តល់អត្ថន័យពន្យល់អំពីមធ្យោបាយដូចម្តេចសម្រាប់ឆ្លើយដោះស្រាយទៅកាន់បន្ទប់រៀន ដែលមានទំនាក់ទំនងជាមួយវប្បធម៌<br>• ចែកផ្តល់ជាកម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវទៅកាន់គ្រូបង្រៀន និង នាយកគ្រប់គ្រងទាំងអស់<br>• ការប្រព្រឹត្តតាមកម្មវិធីស្របតាមការកែសម្រួលអនុសាសន៍ ដែលរាប់បញ្ចូលផងទាំងថ្នាក់ Ethnic Studies សម្រាប់រៀនជាបន្តបន្ទាប់ទៅទៀត<br>• ការកែសម្រួលឯកសារ/ថ្នាក់ និង កម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវ យោងតាមការកែសម្រួលអនុសាសន៍ ដែលត្រូវបានទទួលមកពីការពិនិត្យមើល<br>• ផ្តល់អត្ថន័យពន្យល់ និង ប្រព្រឹត្តតាមមធ្យោបាយអនុវត្តន៍តាមយ៉ាងសក្តិសិទ្ធិសម្រាប់សិស្សរៀនភាសា អង់គ្លេស ដែលរាប់បញ្ចូលផងទាំងការបណ្តុះបណ្តាលកម្មវិធីភាសា អង់គ្លេស ហៅ ELD |

| | | | |
|---|---|---|---|
| **ការដឹកនាំផ្នែកសមធម៌ និង បណ្តុះបណ្តាលប្រាជ្ញា** | គោលដៅនៃការដឹកនាំផ្នែកសមធម៌ និង បណ្តុះបណ្តាលប្រាជ្ញា គឺបង្កើនសមត្ថភាពក្នុងនាមជាអ្នកដឹកនាំយ៉ាងប្រសប់ ដែលជះឥទ្ធិពលទៅកាន់សិស្សតាមរយៈការទទួលស្គាល់វប្បធម៌ កម្មវិធីរាប់បញ្ចូលគ្នា និង ជំនួយគាំទ្រទៅកាន់សិស្សជាម្នាក់ទល់ម្នាក់ ។ | ការិយាល័យ<br>Equity Leadership & Talent Development | • ការពង្រីក និង ប្រើតាមកម្មវិធីរាយផ្សាយពីគ្រូដឹកនាំតាមរយៈជាមួយនាយកគ្រប់គ្រងថ្មី<br>• ការកែសម្រួលកម្មវិធីជាសមធម៌សម្រាប់កម្មវិធីនិមួយៗ យោងតាមការបានត្រួតពិនិត្យផ្នែកសមធម៌នៅតាមក្រសួង<br>• យកចិត្តទុកដាក់មកលើការប្រឹងប្រែងសម្រាប់ទាក់ទាញចំណែកជាមួយផ្នែកសមធម៌ និង ការរក្សាទុក ដូចជាៈ ក្រដាសដាក់ពាក្យ សំនួរ និង កិច្ចការសរសេរ ជាដើម សម្រាប់បុគ្គលិកទាំង ពីរ ក្រុម គឺគ្រូបង្រៀន/នាយកដឹកនាំ និង បុគ្គលិកមិនមែនជាគ្រូបង្រៀន<br>• បង្កើត និង ប្រើតាមប្រព័ន្ធជ្រើសរើសបុគ្គលិកធ្វើការមិនមែនជាគ្រូបង្រៀន ដែលមានថ្មីដៃពិសេស<br>• បង្កើតជាប្រព័ន្ធជួយបង្ហាប់ និង គាំទ្រទៅកាន់បេក្ខជនទាំងអស់ |
| **ទំនាក់ទំនងផ្នែកថវិកា** | គោលដៅនៃទំនាក់ទំនងផ្នែកថវិកា គឺទទួលជាអនុសាសន៍មកវិញអំពីថវិកាតាមរយៈការរួមចំណែកពីសហគមន៍ ដែលបញ្ជាក់អំពីការឆ្លុះបង្ហាញមកលើការប្រើប្រាស់ថវិកា ស្របតាមសមធម៌ និង ធ្វើការដោះស្រាយតាមសេចក្តីត្រូវការរបស់ក្រសួងអប់រំឌីស្ទ្រីគ ។ | ក្រសួងហិរញ្ញវត្ថុ | • បង្កើតការពិគ្រោះជាមួយសហគមន៍អំពីកិច្ចការសំខាន់ៗមុនគេ ដែលត្រូវដោះស្រាយតាមរយៈប្រើថវិកា<br>• បង្កើតចំណេះជាមូលដ្ឋានគ្រិះអំពីរបៀបប្រើថវិកាជាមួយសហគមន៍ ដើម្បីទទួលយកជាគោលយោបល់មកវិញ<br>• បង្កើតជាឱកាសសម្រាប់បំពេញកិច្ចការរួមជាមួយក្រសួងផ្សេងៗ ដែលទាក់ទងមកលើចំនួនសិស្សចុះឈ្មោះចូលរៀន ចំនួនបុគ្គលិក និង ការចែកផ្តល់ជាជំនួយផ្សេងៗទៅតាមសាលារៀន<br>• បង្កើតជាគម្រោងសម្រាប់ប្រើជាច្រើនឆ្នាំទៅមុខបានជាមួយជំនួយបន្ថែមផ្សេងៗ ដែលប៉ះពាល់មកលើអ្វីត្រូវគិតគូរដោះស្រាយមុនគេក្នុងសព្វថ្ងៃនេះ |
| **កន្លែងការងារមានភាពចម្រុះ និង ការអនុវត្តន៍តាមធនធានមនុស្ស** | គោលដៅនៃការអនុវត្តន៍ប្រើធនធានមនុស្ស និង កន្លែងការងារជាភាពចម្រុះ គឺបង្កើតជាការជម្រើសយកថ្មីដៃជាកម្រិតខ្ពស់យ៉ាងចម្រុះ ដើម្បីទាក់ទាញ និង រក្សាទុកបុគ្គលិកសម្រាប់បំពេញមុខងារអោយសមស្របតាមសិស្ស និង សហគមន៍របស់យើង ។ រក្សាទុក និង បង្កើនចំនួនបេក្ខជនជាគ្រូបង្រៀន ដែលមានសមត្ថភាពខ្ពស់ផ្នែកបង្ហាត់ថ្នាក់ K-12 អោយឡើងដល់ 10% សម្រាប់ក្រុមសិស្សមានសម្លេងតិច និង ការបង្កើនជាសមធម៌ និង ឧត្តមភាព ។ | ការិយាល័យ<br>ធនធានមនុស្ស | • ការរែកញែកមើលអំពីរបៀបជួលបុគ្គលិក ការផ្តល់ពិន្ទុមកលើផ្នែកសម្ភាសន៍ ការស្ទង់មើលអំពីលទ្ធផលពីការជួលបុគ្គលិកថ្មីៗ និង ការបង្កើតជារបាយការណ៍ប្រចាំឆ្នាំសម្រាប់ស្ទង់វាស់ និង បង្ហាញភាពលូតលាស់អំពីលទ្ធផលជួលបុគ្គលិកចម្រុះ រួមទាំងរបាយការណ៍អំពីកន្លែងអាចស្វែងរកឃើញបានផង<br>• បង្កើតកិច្ចការជាមួយក្រុមរួមចំណែកផ្សេងៗ និង ទទួលជាគោលយោបល់មកវិញសម្រាប់រាប់ដាក់ទៅក្នុងដំណើរការធ្វើសម្ភាសន៍សម្រាប់បង្កើនផ្នែកសមធម៌<br>• ធ្វើសហការណ៍ជាមួយអនុមហាវិទ្យាល័យ និង វិទ្យាស្ថានកម្រិតខ្ពស់ផ្សេងៗ ដើម្បីទាក់ទាញបុគ្គលិកនៅក្នុងកន្លែងរបស់យើងស្រាប់មកធ្វើការ<br>• បង្កើតការចុះ កុងត្រា ជាមួយគ្រូ ដែលទើបចាប់ផ្តើមមុខងារបង្ហាត់ និង បង្កើតជាលក្ខណសម្រាប់ជ្រើសរើសយកនិស្សិត ស្របតាមថ្នាក់បង្ហាត់ ដែលពួកគេជ្រើសរើសរៀនជាមួយ<br>• បង្កើតជាក្រុមបុគ្គលិកទាក់ទងមកលើសមធម៌ និង បំបាត់ចោលការប្រើអំពើលំអៀង រួមទាំងកម្មវិធីហ្វឹកហ្វឺនការប្រឆាំងអំពើប្រកាន់ពូជសាសន៍សម្រាប់បង្កើតកន្លែងបំពេញការងារជាភាពចម្រុះ |
| **រង្វាស់ និង ឱកាសមិនស្មើគ្នា** | គោលដៅនៃការស្រាវជ្រាវ និង បង្កើនលទ្ធផលសម្រាប់សាលារៀន គឺស្វែងរក និង ផ្តល់អត្ថន័យអំពីសមធម៌ និង គិតគូរមើលជាគំរូសម្រាប់ប្រើសមស្របអ្វីសំខាន់មុនគេ និង បណ្តើមគំនិតមុនគេសម្រាប់សមធម៌ក្នុងក្រសួងអប់រំ ឌីស្ទ្រីគ ។  នាយកដឹកនាំសាលារៀន និង គ្រូបង្រៀននឹងធ្វើការសង្កត់យ៉ាងទៀងទាត់មកលើសមធម៌សម្រាប់ការសម្រេចបង្កើនជាកម្មវិធីអន្តរាគមន៍ និង ការបើកឱកាសផ្សេងៗសម្រាប់ជាលទ្ធផលជោគជ័យដល់សិស្ស ។ | ការិយាល័យស្រាវជ្រាវ និង បង្កើនលទ្ធផល សម្រាប់សាលារៀន | • បណ្តុះបណ្តាលជាអត្ថន័យយ៉ាងច្បាស់លាស់អំពីអ្វីជាមុខងារសំខាន់មុនគេសម្រាប់ស្ទង់វាស់មកលើសមធម៌នៃក្រសួងអប់រំ LBUSD និង ផ្តល់ជាជំនួយទៅកាន់សាលារៀនសម្រាប់ប្រើតាម<br>• បង្កើតគម្រោងច្បាស់លាស់សម្រាប់ប្រើជាប្រព័ន្ធរក្សាទុកលទ្ធផលបានទទួលមកសម្រាប់ប្រើតាមជាគំរូ<br>• ប្រព្រឹត្តតាមទម្រង់ការសម្រាប់លទ្ធផលប្រមូលនៅតាមសាលារៀន ដើម្បីបង្ហាញភាពបង្កើនស្របតាមការស្នើសុំមកលើសំនួរទាក់ទងផ្នែកសមធម៌<br>• ផ្តល់របាយការណ៍ទិន្នន័យរាល់ បី ខែម្តងទៅកាន់ក្រសួងថ្នាក់លើ និង សាលារៀន ដើម្បីគាំទ្រមកលើកម្មវិធីអន្តរាគមន៍ និង ការគិតសម្រេចធ្វើផ្សេងៗ<br>• បង្កើតកម្មវិធីធ្វើការស្ទង់វាស់សម្រាប់កម្រិតថ្នាក់ K-12 និង បណ្តើមគំនិតផ្សេងៗ<br>• ផ្តល់ជារបាយការណ៍ទិន្នន័យសាធារណៈទូទាំងឆ្នាំសិក្សា |
| **ទំនាក់ទំនងផ្នែកពាណិជ្ជកម្ម និង ដៃគូយុទ្ធសាស្រ្ត** | គោលដៅនៃទំនាក់ទំនងផ្នែកពាណិជ្ជកម្ម និង ដៃគូយុទ្ធសាស្រ្ត គឺរក្សាជាដៃគូ និង បង្កើតជាទំនាក់ទំនងពីសិស្សប្រចាំក្រសួងអប់រំ LBUSD ទៅកាន់ពាណិជ្ជកម្ម និង ក្រសួងផ្សេងៗតាមរយៈផ្តល់ឱកាសសម្រាប់បំពេញការងាររៀនធ្វើផ្ទាល់ដៃ ។ | ការិយាល័យទំនាក់ទំនង ផ្នែកពាណិជ្ជកម្ម និង ដៃគូយុទ្ធសាស្រ្ត | • ផ្តល់ឱកាសសម្រាប់ចូលរួមបំពេញការងារផ្ទាល់ដៃស្រមតាមសមធម៌ តាមរយៈបង្កើតដៃគូជាមួយក្រុមហ៊ុន និង កន្លែងការងារផ្សេងៗ<br>• បណ្តុះបណ្តាល និង ធ្វើការទាក់ទងទៅកាន់ក្រុមហ៊ុន និង កន្លែងការងារផ្សេងៗទៀត ដើម្បីសុំអោយពួកគេជួយគាំទ្រមកលើសិស្ស និង បណ្តើមគំនិតរបស់ក្រសួងអប់រំ ឌីស្ទ្រីគ<br>• សមាជិកជាភាពចម្រុះនៅក្នុងក្រុមប្រឹក្សាផ្តល់ឱវាទ<br>• បង្កើតជាឱកាស និង ដំណើរការសម្រាប់ទាក់ទាញចំណែកពីដៃគូពាណិជ្ជកម្មទៅកាន់សិស្សកម្រិតថ្នាក់ K-12 |
| **ការបង្កើនល្បឿនផ្នែកសិក្សា ជំនួយ និង កម្មវិធីជាបន្ថែម** | គោលដៅនៃការបង្កើនល្បឿនផ្នែកសិក្សា ជំនួយ និង កម្មវិធីជាបន្ថែម គឺធ្វើការបញ្ជាក់ថា សិស្សទាំងអស់ពិតជាបានទទួលជំនួយផ្នែកសិក្សា និង ជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តមែនសម្រាប់សេចក្តីជោគជ័យ និង សុខុមាលភាព ។ | ការិយាល័យ<br>Early Learning & Elementary Schools Office, Middle & K-8 Office, High School Office | • ប្រព្រឹត្តតាម គម្រោងបង្កើនល្បឿនសិក្សា និង ផ្តល់ជំនួយទូទៅ សម្រាប់ដោះស្រាយបញ្ហាផ្នែកសិក្សា និង បញ្ហាផ្នែកអារម្មណ៍ និង ផ្លូវចិត្តនៃសិស្ស ដោយប្រើកម្មវិធីអន្តរាគមន៍ ស្របតាមការសិក្សាស្រាវជ្រាវ និង កម្មវិធីពន្យល់មេរៀន អនឡាញ និង ជួបគ្នាផ្ទាល់ សាលារៀនថ្ងៃសៅរ៍ ការរៀនសងពិន្ទុឡើងវិញ និង ឱកាសផ្សេងៗសម្រាប់រៀនជាបន្ថែម<br>• បណ្តុះបណ្តាលជាគំរូសម្រាប់ផ្តល់កម្មវិធីអន្តរាគមន៍ផ្នែករៀនអក្សរ និង លេខចំណោទទៅកាន់សិស្ស (កម្មវិធីរៀនអក្សរនៅតាមសាលាបឋមសិក្សា និង កម្មវិធីអន្តរាគមន៍សម្រាប់លេខចំណោទនៅតាមសាលាមធ្យមសិក្សា)<br>• បង្កើតឱកាសសម្រាប់កម្មវិធីរៀនជាបន្ថែម |